ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៥០ ព.ណ.ស.ន.ច.ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធីក្នុងការស្នើសុំ និងផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១១ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានដើមកំណើតទំនិញ
- បានឃើញអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### ប្រការ១ _ គោលបំណង

ប្រកាសនេះកំណត់អំពីនីតិវិធីក្នុងការស្នើសុំ និងផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ក្នុងគោលបំណងសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃវិធានដើមកំណើតទំនិញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

**ប្រការ២.-** **វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការនាំចេញទំនិញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។

**ប្រការ៣.-** **និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ** សំដៅដល់ទម្រង់ជាក់លាក់មួយដែលចេញដោយអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ និងបញ្ជាក់ថាទំនិញដែលមានក្នុងវិញ្ញាបនបត្រនោះមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- **វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** សំដៅដល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ដែលត្រូវបានប្រើសម្រាប់ការអនុវត្តក្នុងគោលបំណងទទួលបានការអនុគ្រោះពន្ធក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ឬក្រោមប្រព័ន្ធអនុគ្រោះជាឯកតោភាគី។

៣- **វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** សំដៅដល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ដែលត្រូវបានប្រើសម្រាប់ការអនុវត្តក្នុងគោលបំណងមិនមែនប្រព្រឹត្តកម្មអនុគ្រោះពន្ធ។

៤- **លិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ** សំដៅដល់លិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញដែលបញ្ជាក់ថាទំនិញក្នុងលិខិតនោះមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអាចឱ្យអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ប្រើប្រាស់សម្រាប់តាមដានតុល្យភាពសន្និធិ និងទិន្នន័យនៃការនាំចេញទំនិញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក។

៥- **ឧបសម្ព័ន្ធបញ្ជាក់ដើមកំណើតទំនិញ** សំដៅដល់ឧបសម្ព័ន្ធបញ្ជាក់ដើមកំណើតទំនិញ ដែលមិនមែនជាវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ និងលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ដែលអាចឱ្យអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញប្រើប្រាស់សម្រាប់តាមដានតុល្យភាពសន្និធិ និងទិន្នន័យនៃការនាំចេញ។

៦- **អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ** សំដៅដល់ក្រសួងពាណិជ្ជកម្មដែលមានអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មឬអង្គភាពផ្សេងទៀត ដែលទទួលបានសិទ្ធិពីក្រសួងពាណិជ្ជកម្ម ក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទាំងទម្រង់ជាក្រដាស និងទម្រង់អេឡិចត្រូនិក ចំពោះទំនិញនាំចេញ និងគ្រប់គ្រងអ្នកនាំចេញដែលមានការទទួលស្គាល់។

៧- **មន្ត្រីមានសមត្ថកិច្ច** សំដៅដល់មន្ត្រីដែលផ្តល់សេវាសាធារណៈ និងមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ឬអង្គភាពផ្សេងទៀតដែលទទួលបានសិទ្ធិពីក្រសួងពាណិជ្ជកម្ម។

៨- **តុល្យភាពសន្និធិវត្ថុធាតុដើម** សំដៅដល់សមាមាត្ររវាងបរិមាណវត្ថុធាតុដើមនាំចូល និង/ឬវត្ថុធាតុដើមផលិតក្នុងស្រុកជាមួយបរិមាណទំនិញនាំចេញ។

## ជំពូកទី២
## នីតិវិធីនៃការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

**ប្រការ៤.-** **លក្ខខណ្ឌនៃការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ**

ផលិតករ និង/ឬអ្នកនាំចេញ ដែលបានចុះបញ្ជីនាំចេញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ដូចមានកំណត់ក្នុងប្រការ៥ នៃប្រកាសនេះ មានសិទ្ធិស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

**ប្រការ៥.-** **ការចុះបញ្ជីនាំចេញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម**

ការចុះបញ្ជីនាំចេញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវធ្វើឡើងតាមរយៈគេហទំព័រ co.moc.gov.kh ដោយបញ្ចូលព័ត៌មាន និងឯកសារតម្រូវទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ដូចខាងក្រោម៖



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

**ក- ក្រុមហ៊ុនកសិកម្ម និងសិប្បកម្ម**

- ពាក្យស្នើសុំរបស់ផលិតករ និង/ឬអ្នកនាំចេញ (ដូចមានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ)
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងសម្រង់ព័ត៌មាន
- បញ្ជីឈ្មោះមុខទំនិញនាំចេញ
- កិច្ចសន្យាទិញលក់
- ប័ណ្ណពន្ធប៉ាតង់ប្រចាំឆ្នាំចុងក្រោយ
- កិច្ចសន្យាជួលទីតាំង ឬបណ្ណកម្មសិទ្ធិ
- លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ
- ក្នុងករណីជាតំណាង ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិពីប្រធានក្រុមហ៊ុន ឬនាយកគ្រប់គ្រង (ដូចមានក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ)។

**ខ- ក្រុមហ៊ុនវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ សម្ភារធ្វើដំណើរនិងកាបូប និងក្រុមហ៊ុនផលិតផលិតផលផ្សេងៗ**

- ពាក្យស្នើសុំរបស់ផលិតករ និង/ឬអ្នកនាំចេញ (ដូចមានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ)
- ក្នុងករណី ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវភ្ជាប់លិខិតចុះបញ្ជីគម្រោងវិនិយោគរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងសម្រង់ព័ត៌មាន
- បញ្ជីឈ្មោះមុខទំនិញនាំចេញ
- តារាងលម្អិតថ្លៃដើមផលិតផល (ដូចមានក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ) ឬកិច្ចសន្យាទិញលក់
- ប័ណ្ណពន្ធប៉ាតង់ប្រចាំឆ្នាំចុងក្រោយ
- ក្នុងករណី ក្រុមហ៊ុនវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងសម្ភារធ្វើដំណើរនិងកាបូប ត្រូវភ្ជាប់វិញ្ញាបនបត្រសមាជិកភាពសមាគម និង/ឬវិញ្ញាបនបត្រចុះបញ្ជីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC)
- កិច្ចសន្យាជួលទីតាំង ឬបណ្ណកម្មសិទ្ធិ
- លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ
- ក្នុងករណីជាតំណាង ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិពីប្រធានក្រុមហ៊ុន ឬនាយកគ្រប់គ្រង (ដូចមានក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ)។

បន្ទាប់ពីបានទទួលពាក្យស្នើសុំចុះបញ្ជីនាំចេញ មន្ត្រីមានសមត្ថកិច្ចត្រូវចុះពិនិត្យអាជីវកម្មដ្ឋាន ឬទីតាំងផលិត និងកន្លែងប្រមូលទិញឬឃ្លាំងស្តុកទំនិញ យ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោងនៃម៉ោងធ្វើការ ឬ ៤៨ (សែសិបប្រាំបី) ម៉ោងនៃម៉ោងធ្វើការ សម្រាប់បណ្តាអាជីវកម្មដ្ឋាន ឬទីតាំងផលិតដែលនៅឆ្ងាយពីរាជធានីភ្នំពេញ។ ក្រោយពីការចុះត្រួតពិនិត្យ មន្ត្រីមានសមត្ថកិច្ច ត្រូវធ្វើរបាយការណ៍ចុះពិនិត្យទីតាំង។ របាយការណ៍នេះ ជាកម្មវត្ថុនៃការពិនិត្យនិងសម្រេចលើការចុះបញ្ជីនាំចេញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។

ក្នុងករណីមានការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងនាមករណ៍ ទីតាំង ឬមុខទំនិញ ផលិតករ និង/ឬអ្នកនាំចេញ ត្រូវដាក់ពាក្យស្នើសុំផ្លាស់ប្តូរព័ត៌មានទាំងនោះមកក្រសួងពាណិជ្ជកម្ម ដើម្បីទទួលបានសិទ្ធិនាំចេញបន្ត។

**ប្រការ៦ _ វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (Certificate of Origin – CO)**

ផលិតករ និង/ឬអ្នកនាំចេញ ដែលទទួលបានសិទ្ធិដូចមានកំណត់ក្នុងប្រការ៤ ត្រូវស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ តាមរយៈគេហទំព័រ co.moc.gov.kh ។

ផលិតករ និង/ឬអ្នកនាំចេញ ត្រូវបញ្ចូលព័ត៌មាន និងឯកសារតម្រូវទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ដូចខាងក្រោម៖

- វិក្កយបត្រ និងតារាងវេចខ្ចប់
- តារាងលម្អិតថ្លៃដើមផលិតផល (ដូចមានក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ) ឬឯកសារយោងតាមការកំណត់របស់វិធានដើមកំណើតទំនិញ។

**ប្រការ៧ _ ការផ្ទៀងផ្ទាត់ តម្កល់ទុក និងឧបសម្ព័ន្ធបញ្ជាក់ដើមកំណើតទំនិញ (CO Reference Form-CRF)**

ដើម្បីផ្ទៀងផ្ទាត់ តម្កល់ទុក និងបំពេញឧបសម្ព័ន្ធបញ្ជាក់ដើមកំណើតទំនិញ ផលិតករ និង/ឬអ្នកនាំចេញ ត្រូវផ្តល់ឯកសារមកអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញវិញ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ តាមរយៈគេហទំព័រ co.moc.gov.kh គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ចំពោះអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល ឬដៃគូពាណិជ្ជកម្ម ដែលមានតម្រូវវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ និងគិតចាប់ពីថ្ងៃចេញទំនិញពីកម្ពុជា ចំពោះអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល ឬដៃគូពាណិជ្ជកម្ម ដែលពុំមានតម្រូវវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ដូចមានកំណត់ខាងក្រោម៖

**ក- ទំនិញកសិកម្ម និងកសិកម្មកែច្នៃផ្សេងទៀត៖**

- វិក្កយបត្រ និងតារាងវេចខ្ចប់
- អញ្ញាតបណ្ណដឹកជញ្ជូន ឬឯកសារពាក់ព័ន្ធបញ្ជាក់ពីការនាំចេញទំនិញ
- កិច្ចសន្យាទិញលក់ ឬឯកសារប្រហាក់ប្រហែល។

**ខ- ទំនិញសម្លៀកបំពាក់ វាយនភណ្ឌ ស្បែកជើង សម្ភារធ្វើដំណើរនិងកាបូប និងទំនិញផ្សេងទៀត៖**

- វិក្កយបត្រ និងតារាងវេចខ្ចប់
- អញ្ញាតបណ្ណដឹកជញ្ជូន
- ប្រតិវេទន៍គយ
- អាជ្ញាបណ្ណនាំចេញសម្រាប់ទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់។

ការផ្តល់ឯកសារសម្រាប់ផ្ទៀងផ្ទាត់ តម្កល់ទុក និងការបំពេញឧបសម្ព័ន្ធបញ្ជាក់ដើមកំណើតទំនិញ ពុំតម្រូវឱ្យមានការបង់កម្រៃសេវាសាធារណៈឡើយ។

**ប្រការ៨ _ លិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ (Origin Certification Letter – OCL)**

ក្នុងករណីផលិតករ និង/ឬអ្នកនាំចេញ ដែលនាំចេញទំនិញទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក ត្រូវអនុវត្តតាមប្រកាសស្តីពីនីតិវិធីក្នុងការស្នើសុំ និងការចេញលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញសម្រាប់ការនាំចេញទំនិញមួយចំនួនទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក ជាធរមាន។

**ប្រការ៩ _ ការចុះត្រួតពិនិត្យទំនិញនាំចេញលើកដំបូង**

ចំពោះអ្នកនាំចេញលើកដំបូង ដែលបានចុះបញ្ជីនាំចេញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មរួចរាល់ ផលិតករ និង/ឬអ្នកនាំចេញ ត្រូវដាក់ពាក្យស្នើសុំត្រួតពិនិត្យទំនិញនាំចេញលើកដំបូង មកអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

បន្ទាប់ពីទទួលបានពាក្យស្នើសុំចុះត្រួតពិនិត្យទំនិញនាំចេញ មន្ត្រីមានសមត្ថកិច្ចនឹងចុះពិនិត្យខ្សែច្រវាក់ផលិតកម្ម ទីតាំងប្រមូលទិញ ឃ្លាំងស្តុកទំនិញ និងទំនិញនាំចេញ យ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោងនៃម៉ោងធ្វើការ ឬ ៤៨ (សែសិបប្រាំបី) ម៉ោងនៃម៉ោងធ្វើការសម្រាប់បណ្តាអាជីវកម្មដ្ឋាន ឬទីតាំងផលិតដែលនៅឆ្ងាយពីរាជធានីភ្នំពេញ ហើយស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

## ប្រការ១០.- ការចុះត្រួតពិនិត្យទំនិញមុនការនាំចេញ

ផលិតករ និង/ឬអ្នកនាំចេញ ត្រូវដាក់ពាក្យស្នើសុំត្រួតពិនិត្យទំនិញមុនការនាំចេញ មកអាជ្ញាធរចេញវិញ្ញាបនបត្រ បញ្ជាក់ដើមកំណើតទំនិញ លើមុខទំនិញដូចខាងក្រោម៖

- ទំនិញនាំចេញតាមជើងយន្តហោះបន្ទាប់ពីដឹកជញ្ជូនតាមរថយន្តឆ្លងកាត់ព្រំដែនកម្ពុជា
- សម្លៀកបំពាក់ពណ៌ប៉ាក់ ពណ៌បៃតងឬត្រែអ៊ី និងពណ៌កាគី
- ទំនិញកម្មេចក្រណាត់ឬសម្លៀកបំពាក់បាតឃ្លាំង និង
- ទំនិញកសិកម្ម និងផលិតផលកសិ-កែច្នៃ ដូចមានក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

## ប្រការ១១.- ការចុះត្រួតពិនិត្យទំនិញក្រោយការនាំចេញ

ផលិតករ និង/ឬអ្នកនាំចេញ ត្រូវដាក់ពាក្យស្នើសុំត្រួតពិនិត្យទំនិញក្រោយការនាំចេញ ដូចមានក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការនាំចេញ មកអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញលើមុខទំនិញដែលបានប្រើប្រាស់វត្ថុធាតុដើមនាំចូល។

# ជំពូកទី៣
# ការគ្រប់គ្រងសន្និធិវត្ថុធាតុដើមសម្រាប់បម្រើឱ្យផលិតកម្ម

## ប្រការ១២.- លក្ខខណ្ឌ និងឯកសារតម្រូវក្នុងការប្រកាសសន្និធិវត្ថុធាតុដើម

ផលិតករ និង/ឬអ្នកនាំចេញ ត្រូវប្រកាសសន្និធិវត្ថុធាតុដើមនាំចូល និងវត្ថុធាតុដើមផលិតក្នុងស្រុកសម្រាប់បម្រើផលិតកម្ម តាមរយៈគេហទំព័រ co.moc.gov.kh សម្រាប់ស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ឬឧបសម្ព័ន្ធបញ្ជាក់ដើមកំណើតទំនិញ ឬលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ។ ផលិតករ និង/ឬអ្នកនាំចេញ ត្រូវភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម៖

### ក- វត្ថុធាតុដើមនាំចូល

- វិក្កយបត្រ និងតារាងវេចខ្ចប់
- អញ្ញាតបណ្ណដឹកជញ្ជូន
- ប្រតិវេទន៍គយ និង
- សំអាងដើមកំណើតទំនិញ។

### ខ- វត្ថុធាតុដើមផលិតក្នុងស្រុក

- កិច្ចសន្យាទិញលក់
- វិក្កយបត្រ និងតារាងវេចខ្ចប់ និង
- របាយការណ៍របស់មន្ត្រីមានសមត្ថកិច្ចស្តីពីការត្រួតពិនិត្យខ្សែច្រវាក់ផលិតកម្មរបស់ក្រុមហ៊ុនផ្គត់ផ្គង់។

## ប្រការ១៣.- ការផ្ទៀងផ្ទាត់តុល្យភាពសន្និធិវត្ថុធាតុដើម

ផលិតករ និង/ឬអ្នកនាំចេញ បន្ទាប់ពីទទួលបានវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ឬឧបសម្ព័ន្ធបញ្ជាក់ដើមកំណើតទំនិញ ឬលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញ ត្រូវបញ្ចូលព័ត៌មានផ្ទៀងផ្ទាត់តុល្យភាពសន្និធិវត្ថុធាតុដើម តាមរយៈគេហទំព័រ co.moc.gov.kh ដោយភ្ជាប់តារាងរបាយការណ៍ស្តីពីបទដ្ឋានប្រើប្រាស់វត្ថុធាតុដើម ដូចមានក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសនេះ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនាំចេញទំនិញ។

ផលិតករ និង/ឬអ្នកនាំចេញ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច ក្នុងការធ្វើសវនកម្មលើសន្និធិវត្ថុធាតុដើមនៅអាជីវកម្មដ្ឋាន ឬទីតាំងផលិតចំនួន ២ (ពីរ) លើកក្នុងមួយឆ្នាំ។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

## ជំពូកទី៤
## កម្រៃសេវាសាធារណៈ

**ប្រការ១៤ _ ការទូទាត់កម្រៃសេវាសាធារណៈ**

ផលិតករ និង/ឬអ្នកនាំចេញ ត្រូវបង់កម្រៃសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក តាមការកំណត់ក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ជាធរមាន។

បង្កាន់ដៃបង់ប្រាក់ត្រូវបោះពុម្ពចេញ ឬរក្សាទុកជាទម្រង់អេឡិចត្រូនិក ដើម្បីជាភស្តុតាងបញ្ជាក់ពីការទូទាត់ប្រាក់រួចរាល់។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ១៥ _ ការបន្តសុពលភាពវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ**

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញដែលបានចេញមុនប្រកាសនេះដាក់ឱ្យអនុវត្ត ត្រូវបន្តមានសុពលភាពដដែល។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៦ _ ការទុកជានិរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧ _**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាននាំចេញ នាំចូល ប្រធាននាយកដ្ឋានគ្រប់គ្រងការនាំចេញក្នុងតំបន់សេដ្ឋកិច្ចពិសេស ប្រធានគ្រប់នាយកដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៥រោច ខែ បឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ១៧

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទំនាក់ទំនង៖ ១២៦៦

អ៊ីម៉ែល៖ cabinet.info@moc.gov.kh

**ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ** ០៥០ ពណ.សសខ.ប្រក **ចុះថ្ងៃទី** ១ **ខែ** មករា **ឆ្នាំ២០២៦**

# ឈ្មោះក្រុមហ៊ុន

អាសយដ្ឋាន និងលេខទូរសព្ទទំនាក់ទំនង

---

លេខ.....................

**សូមគោរពជូន**

**លោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ** ៖ សំណើសុំចុះបញ្ជីនាំចេញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម តាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **លោកជំទាវរដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំមានបំណងនាំចេញទំនិញ...........................ទៅកាន់ទីផ្សារបរទេសក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។

ខ្ញុំបាទ/នាងខ្ញុំសូមធានាថាការបញ្ចូលព័ត៌មានទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម និងឯកសារភ្ជាប់ពិតជាត្រឹមត្រូវប្រាកដមែន ហើយសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់។ ករណីមានការផ្លាស់ប្តូរព័ត៌មាន ខ្ញុំបាទ/នាងខ្ញុំនឹងជូនដំណឹងមកក្រសួងពាណិជ្ជកម្មជាបន្តបន្ទាប់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **លោកជំទាវរដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ៕

ថ្ងៃ........................ខែ...........ឆ្នាំ......................... ព.ស.២៥......

.................... ថ្ងៃទី.........ខែ.............ឆ្នាំ២០.....

**តំណាងក្រុមហ៊ុន**

(ហត្ថលេខានិងត្រា)

**ឈ្មោះ**

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម

**ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ** ០៤០ ពាណ.ន.សជ.ប្រក **ចុះថ្ងៃទី** ១ **ខែ** កញ្ញា **ឆ្នាំ២០២៦**

# ឈ្មោះក្រុមហ៊ុន

អាសយដ្ឋាន និងលេខទូរសព្ទទំនាក់ទំនង

---

លេខ.............................

(រូបថត៤x៦ ប្រធានក្រុមហ៊ុន ឬនាយកគ្រប់គ្រង)

**សូមគោរពជូន**
**លោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

## លិខិតប្រគល់សិទ្ធិ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..................................ជាប្រធានក្រុមហ៊ុន/នាយកគ្រប់គ្រង.....................................។ សូមប្រគល់សិទ្ធិជូនឈ្មោះដូចមានរាយនាមខាងក្រោម៖

| ល.រ | រូបថត | ព័ត៌មានផ្ទាល់ខ្លួន | តួនាទី | គំរូហត្ថលេខា |
|---|---|---|---|---|
| ១ | (រូបថត៤x៦) | -ឈ្មោះ៖................................<br>-ភេទ៖..................................<br>-អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន៖<br>..........................................<br>-ទូរសព្ទ៖..............................<br>-អ៊ីមែល៖.............................. | ☐ បំពេញបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ<br>☐ ចុះហត្ថលេខាលើវិក្កយបត្រ និងតារាងវេចខ្ចប់<br>☐ ចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ | |
| ២ | (រូបថត៤x៦) | -ឈ្មោះ៖................................<br>-ភេទ៖..................................<br>-អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន៖<br>..........................................<br>-ទូរសព្ទ៖..............................<br>-អ៊ីមែល៖.............................. | ☐ បំពេញបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ<br>☐ ចុះហត្ថលេខាលើវិក្កយបត្រ និងតារាងវេចខ្ចប់<br>☐ ចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ | |
| ... | | | | |

ខ្ញុំបាទ/នាងខ្ញុំសូមទទួលខុសត្រូវទាំងស្រុង នូវរាល់ទង្វើផ្ទុយពីច្បាប់និងបទប្បញ្ញត្តិជាធរមាន របស់បុគ្គលទទួលសិទ្ធិដូចមានរាយនាមខាងលើផងដែរ។

**បញ្ជាក់៖** រាល់បុគ្គលដែលបានទទួលសិទ្ធិកន្លងមកត្រូវទុកជានិរាករណ៍ និងលិខិតប្រគល់សិទ្ធិនេះមានតម្លៃប្រើប្រាស់ចាប់ពីពេលប្រគល់សិទ្ធិនេះរហូតដល់មានការជូនដំណឹងជាថ្មី។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវរដ្ឋមន្ត្រី** មេត្តាអនុញ្ញាត និងទទួលស្គាល់ដោយសេចក្តីអនុគ្រោះ។

សូម **លោកជំទាវរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ៕

ថ្ងៃ....................ខែ...........ឆ្នាំ......................ព.ស.២៥.....

..................... ថ្ងៃទី.......ខែ..............ឆ្នាំ២០....

ប្រធានក្រុមហ៊ុន/នាយកគ្រប់គ្រង

(ហត្ថលេខានិងត្រា)

ឈ្មោះ

គំរូលិខិតប្រគល់សិទ្ធិ

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ ០៥០ ពណ.ន.ស/ប្រក ចុះថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ២០២៦

# COST BREAKDOWN STATEMENT FOR THE EXPORT OF PRODUCT

Name of Manufacturer : ____________________

Description of Product : ____________________ HS Code: ____________________

Model No : ____________________ Unit Price: ____________ (FOB-USD)

Country of Destination : ____________________

This Cost Statement is for _____ Unit(s) Date of Cost Statement : _____

| | HS Code | Country of Origin | Supplier' s Name (if Locally Manufactured) | Unit Cost (CIF) | | | |
|---|---|---|---|---|---|---|---|
| | | | | Local | Foreign | FTA Member | Total |
| 1. Raw Materials, Parts & Components (Please give detailed breakdown)<br>a)<br>b)<br>c)<br>d) | | | | | | | |
| 2. Direct Labour Cost:<br>Wages<br>Other benefits<br>(Insurance, Medical benefits etc)<br>(Please give detailed breakdown) | | | | | | | |
| 3. Direct Overhead Cost:<br>(eg Factory rent, Depreciation costs, Maintenance)<br>(Please give detailed breakdown) | | | | | | | |
| 4. Ex-Factory Cost (1+2+3) | | | | | | | |
| 5. Profit | | | | | | | |
| 6. Ex-Factory Price (4+5) | | | | | | | |

Calculations:

**1. Single Country Content** = $\frac{\text{Local Material Cost + Direct Labour \& Direct Overheads + Profit}}{\text{FOB Price}}$ x 100 = ______ %

OR

**2. FTA Cumulative Content** = $\frac{\text{Local, FTA Member Material Cost + Direct Labour \& Direct Overheads + Profit}}{\text{FOB Price}}$ x 100 = ______ %

OR

**3. Value or Ad Valorem Criterion** = $\frac{\text{Local Material Cost + Direct Labour \& Direct Overheads + Profit}}{\text{Ex-Factory Price}}$ x 100 = ______ %

Declaration : I declare that the information provided is true and correct.

This cost statement is prepared by:

____________________ ____________________

Name (Director/Managing Director) Signature & Stamp

Date : ____________________

Name (Accountant) & Signature

Date : ____________________

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ ០៥០ ពណ.សន.ប្រក ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ២០២៦

## បញ្ជីទំនិញកសិកម្ម និងផលិតផលកសិ-កែច្នៃ ដែលស្ថិតក្រោមការចុះត្រួតពិនិត្យមុនការនាំចេញ

| ល.រ | មុខទំនិញ | Goods |
|---|---|---|
| ១ | ស្វាយចន្ទី | Cashew nut |
| ២ | ដំឡូងមី | Cassava |
| ៣ | ជ័រកៅស៊ូ | Rubber |
| ៤ | ចេក | Banana |
| ៥ | ស្វាយ | Mango |
| ៦ | ដូងប្រេង | Palm oil |
| ៧ | ម្រេច | Pepper |
| ៨ | មៀន | Longan |
| ៩ | ទុរេន | Durian |
| ១០ | ស្ករ | Sugar |
| ១១ | រមៀត | Turmeric |
| ១២ | ថ្នាំជក់ | Tobacco |
| ១៣ | សណ្តែកសៀង | Soya bean |
| ១៤ | ពោត | Corn |

*កំណត់សម្គាល់៖ បញ្ជីទំនិញកសិកម្ម និងផលិតផលកសិ-កែច្នៃខាងលើនេះបញ្ចប់ត្រឹមលេខរៀងទី១៤ និងអាចធ្វើបច្ចុប្បន្នភាពតាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម។*

ឧបសម្ព័ន្ធទី៥ នៃប្រកាសលេខ ០៥០ ពណ.ន.គជ.ប្រក ចុះថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០២៦

## បញ្ជីទំនិញដែលស្ថិតក្រោមការចុះត្រួតពិនិត្យក្រោយការនាំចេញ

| ល.រ | មុខទំនិញ | Goods |
|---|---|---|
| ១ | សម្លៀកបំពាក់ | Apparel |
| ២ | សម្ភារធ្វើដំណើរ និងកាបូប | Travel Goods and Bags |
| ៣ | ស្បែកជើង និងភាគបំណែកស្បែកជើង | Shoes and Other Parts |
| ៤ | វាយនភណ្ឌ | Textiles |
| ៥ | គ្រឿងបង្គុំអេឡិចត្រូនិក | Electronic Component and Parts |
| ៦ | បន្ទះសូឡា | Solar Panel |
| ៧ | ចង្កៀង អំពូល និងបរិធានបំភ្លឺ | Luminaires, Lighting and Parts |
| ៨ | ទោចក្រយាន និងគ្រឿងបង្គុំ | Bicycles and Parts |
| ៩ | ប្រដាប់ក្មេងលេង ល្បែងកម្សាន្ត និងសម្ភារកីឡា | Toys, Games, and Sports Equipment |
| ១០ | សំបកកង់រថយន្ត | Car Tires |
| ១១ | ស្រោមដៃជ័រ | Rubber Gloves |
| ១២ | គ្រឿងសង្ហារឹម កៅអី និងបំណែកភាគ | Furniture, Seats, and Parts |
| ១៣ | ស្បែកសត្វ | Raw Hides, Skins and Fur Skins |
| ១៤ | ឈើ និងផលិតផលពីឈើ | Wood and Other Wood Products |
| ១៥ | ក្រដាស និងក្រដាសកាតុង | Paper and Paperboard |
| ១៦ | លោហៈធាតុ និងវត្ថុធ្វើពីលោហៈធាតុ | Metals and Articles Thereof |
| ១៧ | វត្ថុធ្វើពីប្លាស្ទិក | Articles of Plastic |
| ១៨ | ឈុតសម្ភារប្រើប្រាស់សម្រាប់ធ្វើដំណើរ | Personal Travel Sets |
| ១៩ | គ្រឿងក្រអូប គ្រឿងសម្អាង គ្រឿងសម្អាតកាយ និងសាប៊ូ | Perfumery, Cosmetics, Toiletries, and Washing Products |
| ២០ | ឆត្រ | Umbrellas |
| ២១ | ក្រាស ដង្កៀបសក់ និងប្រដាប់រមូរសក់ | Combs, Hair-Slides, and Hair Curlers |
| ២២ | បារី | Cigarettes |

*កំណត់សម្គាល់៖ បញ្ជីទំនិញខាងលើនេះបញ្ចប់ត្រឹមលេខរៀងទី២២ និងអាចធ្វើបច្ចុប្បន្នភាពតាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម។*

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម

**ឧបសម្ព័ន្ធទី៦ នៃប្រកាសលេខ** ០៧០ ពណ.ស.ន៨.ប្រក **ចុះថ្ងៃទី** ៧ **ខែ**មករា **ឆ្នាំ២០២៦**

# ឈ្មោះក្រុមហ៊ុន

អាសយដ្ឋាន និងលេខទូរសព្ទទំនាក់ទំនង

---

**គោរពជូន**

**លោកប្រធាននាយកដ្ឋាននាំចេញ នាំចូល ឬ**

**លោកប្រធាននាយកដ្ឋានគ្រប់គ្រងការនាំចេញក្នុងតំបន់សេដ្ឋកិច្ចពិសេស**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីបទដ្ឋានប្រើប្រាស់វត្ថុធាតុដើម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំបាន (នាំចូលវត្ថុធាតុដើមនិងទិញក្នុងស្រុក / ប្រើប្រាស់វត្ថុធាតុដើមសម្រាប់ផលិតទំនិញនាំចេញទៅបរទេស) ដូចខាងក្រោម៖

| ល.រ | វត្ថុធាតុដើមនាំចូល / ទំនិញនាំចេញ | | | | | វិក្កយបត្រ | ប្រតិវេទន៍គយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | លេខកូដ (៦ខ្ទង់) | បរិយាយ | ឯកតា | ទម្ងន់ (KGS) | ទឹកប្រាក់ (USD) | | | |
| ១ | | | | | | | | |
| ២ | | | | | | | | |
| ... | | | | | | | | |

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពពីខ្ញុំបាទ/នាងខ្ញុំ៕

ថ្ងៃ.......................ខែ...........ឆ្នាំ.................... ព.ស.២៥......

...................... ថ្ងៃទី.......ខែ.............ឆ្នាំ២០.....

**តំណាងក្រុមហ៊ុន**

(ហត្ថលេខានិងត្រា)

**ឈ្មោះ**